ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តមណ្ឌលគិរី

សំណុំរឿងរដ្ឋប្បវេណីលេខ: ១៨

ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០

សាលក្រមរដ្ឋប្បវេណីលេខ: ១៨

ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តមណ្ឌលគិរី

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១

និងប្រកាសសាលក្រមនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តមណ្ឌលគិរី

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តមណ្ឌលគិរី

រវាងដើមចោទ

-ឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]

-មេធាវីតំណាងដោយអាណត្តិ៖ លោក [redacted] អត្តលេខ ២៣២៧។

និងចុងចម្លើយ

-ឈ្មោះ [redacted]វ៉ាន ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted]។

-មេធាវីតំណាងដោយអាណត្តិ៖ គ្មាន។

## អង្គហេតុ និងចំណុចវិវាទ

**១.ការទាមទាររបស់ដើមចោទ:** ដើមចោទបានប្តឹងសុំឱ្យតុលាការចេញសាលក្រម៖

-ឱ្យនាងខ្ញុំបានលែងលះជាមួយឈ្មោះ [redacted]វ៉ាន។

-ឱ្យនាងខ្ញុំមានសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted]វឌ្ឍន: ភេទប្រុស អាយុ ០៣ខែ។

-បំណុលធនាគារចំនួន ៧,០០០$ (ប្រាំពីរពាន់ដុល្លារ) ឱ្យឈ្មោះ [redacted]វ៉ាន ជាអ្នកសង។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី:**

កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ នាងខ្ញុំបានរៀបចំអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted]វ៉ាន ភេទប្រុស ហើយបានរស់នៅជាមួយគ្នារហូតដល់ពេលបច្ចុប្បន្ន និងមានកូនចំនួន ០១នាក់ឈ្មោះ [redacted] វឌ្ឍន: ភេទប្រុស អាយុ ១៨ខែ និងជំពាក់បំណុលធនាគារចំនួន ៧.០០០(ប្រាំពីរពាន)ដុល្លារអាមេរិក។ ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នា និងពិបាកក្នុងការរស់នៅជាមួយគ្នាប្តីប្រពន្ធតទៅទៀត ទើបនាងខ្ញុំសម្រេចចិត្ត ដាក់ពាក្យបណ្តឹងមកតុលាការ សូមឱ្យតុលាការមេត្តាចេញសាលក្រមតាមការទាមទារខាងលើនេះ។

**៣.ការអះអាងរបស់គូភាគី:**

៣.១.ការអះអាងរបស់ដើមចោទ

ដើមចោទឈ្មោះ [redacted] លក្ខិណា បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួននៅតែរក្សាការទាមទារដូចមានក្នុងកម្មវត្ថុនៃបណ្តឹង ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ដដែល ដោយទាមទារ៖

-ឱ្យខ្លួនបានលែងលះជាមួយឈ្មោះ [redacted]វ៉ាន ។

-ឱ្យខ្លួនមានសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted]វឌ្ឍន: ភេទប្រុស អាយុ០៣ខែ។

-បំណុលធនាគារចំនួន ៧,០០០$ (ប្រាំពីរ ពាន់)ដុល្លារ ឱ្យឈ្មោះ [redacted]វ៉ាន់ ជាអ្នកសង។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

រីឯមូលហេតុនៃការទាមទារ៖ យើងខ្ញុំទាំងពីរនាក់ បានរៀបអាពាហ៍ពិពាហ៍ និងចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៩ ហើយពេលនេះ នាងខ្ញុំអស់មនោសញ្ចេតនាពីប្តីទៀតហើយ។

-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ សូមឱ្យតុលាការចេញ សាលក្រមតាមការទាមទាររបស់កូនក្តីខ្ញុំ ដូចមានចុះក្នុងពាក្យបណ្តឹងស្រាប់។ មូលហេតុដែលកូនក្តីរបស់ខ្ញុំបាទទាមទារសិទ្ធិជាអំណាចមេបាលើកូនឈ្មោះ [redacted] វឌ្ឍន: ពីព្រោះកូនក្តីរបស់ខ្ញុំបាទមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់មើលថែទាំ និងអោយកូនបានចូលសិក្សារៀនសូត្រដើម្បីអោយក្លាយជាកូនល្អ សិស្សល្អ នៅក្នុងសង្គមបាន។ ម៉្យាងទៀតក្នុងពេលដែលកូនក្តីរបស់ខ្ញុំបាទចិញ្ចឹមមើលថែទាំកូន គឺភាគីចុងចម្លើយមិនដែលផ្តល់ប្រាក់កាក់ ឬមកមើលកូនរបស់ខ្លួនឡើយ ហេតុនេះប្រសិនបើតុលាការសម្រេចឱ្យភាគីចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted]វឌ្ឍន: នោះខ្ញុំបាទគិតថា ភាគីចុងចម្លើយមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ និងមើលថែទាំកូនអោយបានរៀនសូត្របានជិតដល់ដូចកូនក្តីរបស់ខ្ញុំបាទនោះទេ។

ចំពោះបំណុលពីមុនចំនួន ៧.០០០$(ប្រាំពីរពាន់)ដុល្លាអាមេរិករួមមាន៖(ធនាគារអេស៊ីលីដាចំនួន២.០០០$ និងធនាគារប្រាសាក់ចំនួន៥.០០០$) គឺសុំអោយភាគីចុងចម្លើយ ជាអ្នកទទួលរ៉ាប់រងតែម្នាក់ឯង ពីព្រោះនៅមុនពេលកម្ចីប្រាក់ពីធនាគារទាំងពីរស្ថាប័ន គឺភាគីចុងចម្លើយបានលួមលោម និងបង្ខំកូនក្តីរបស់ខ្ញុំបាទឱ្យយកប្លង់ដីដែលជាកម្មសិទ្ធិរបស់កូនក្តីខ្ញុំបាទទៅដាក់បញ្ចាំ ហើយបាននិយាយថានៅពេលខ្ចីប្រាក់បានហើយ គឺគាត់ (ភាគីចុងចម្លើយ) យកប្រាក់នោះទៅរកស៊ី និងទិញដីទុក។ នៅពេលខ្ចីប្រាក់បានហើយភាគីចុងចម្លើយបានយកប្រាក់នោះទាំងអស់រួចលួចទៅទិញដីដាក់ឈ្មោះជាកម្មសិទ្ធិតែម្នាក់ឯង។

រហូតមកដល់សព្វនេះ កូនក្តីរបស់ខ្ញុំបាទ បានទូទាត់ការប្រាក់ និងប្រាក់ដើមជាមួយនឹងធនាគារអេស៊ីលីដារួចរាល់អស់ហើយ ចំពោះប្រាក់កម្ចីនៅធនាគារប្រាសាក់ គឺកូនក្តីរបស់ខ្ញុំបាទបានទូទាត់នៅសល់បំណុលតែ ៤.០០០ (បួនពាន់) ដុល្លាអាមេរិកតែប៉ុណ្ណោះ។ សរុបមកកូនក្តីខ្ញុំបាទ គឺគាត់មានលទ្ធិភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់មើលថែទាំកូន និងអោយកូនបានចូលសិក្សារៀនសូត្រ ដើម្បីអោយក្លាយជាកូនល្អ សិស្សល្អនៅក្នុងសង្គមបាន។ ចំពោះបំណុលវិញ គឺកូនក្តីខ្ញុំបាទក៏បានជួយទូរទាត់ទាំងការប្រាក់ និងប្រាក់ដើមទៅធនាគារវិញបានមួយចំនួនផងដែរ។ ចំពោះអាហារកាតព្វកិច្ចចិញ្ចឹមកូនគឺ កូនក្តីរបស់ខ្ញុំបាទ ពុំទាមទារនោះទេ។

យោងតាមមាត្រា ៩៧៨ មូលហេតុនៃការលែងលះគ្នា ត្រង់កថាខណ្ឌទី១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី



Scanned with CamScanner

បានចែងថា បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ អស់រយៈពេល០១ (មួយ)ឆ្នាំ ផ្ទុយនឹងគោលបំណង នៃអាពាហ៍ពិពាហ៍។ ត្រង់មាត្រានេះតាមអង្គហេតុឃើញថាកូនក្តីរបស់ខ្ញុំបាទ និងភាគីចុងចម្លើយ ពិតជារស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេល០១(មួយ)ឆ្នាំ ជាងពិតប្រាកដមែន ស្របតាមមាត្រានេះអាចឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្ញុំបាទ និងភាគីចុងចម្លើយលែងលះគ្នាបាន។

យោងតាមមាត្រា ១០៣៧ ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា ត្រង់កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី បានចែងថា បើការពិភាក្សានៃកថាខណ្ឌទី១ ឬកថាខណ្ឌទី២ ខាងលើនេះ ពុំបានសម្រេច ឬបើពុំអាចពិភាក្សាបានទេតុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍កូននោះ និងមាត្រា១០៤៣ ការអប់រំកូន នៃក្រមរដ្ឋប្បវេណី បានចែងថា អ្នកមានអំណាចមេបា មានសិទ្ធិ និងករណីយកិច្ចអប់រំកូន។ ស្របតាមអង្គហេតុខាងលើឃើញថា សព្វថ្ងៃនេះ កូនក្តីរបស់ខ្ញុំបាទ កំពុងតែមានកាតព្វកិច្ចចិញ្ចឹមបីបាច់មើលថែទាំកូនតាំងពីចាប់កំណើតមកម្ល៉េះ ហេតុនេះ កូនក្តីរបស់ខ្ញុំបាទ ពិតជាមានលទ្ធិភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើជាអំណាចមេបា យ៉ាងពិតប្រាកដ។

យោងមាត្រា៩៧៥ ការទទួលខុសត្រូវដោយសាមគ្គីភាព ចំពោះកាតព្វកិច្ច ត្រង់ចំណុចខ នៃក្រមរដ្ឋប្បវេណីបានចែងថា កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗ ទៀត ដែលប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរជាមួយម្ចាស់បំណុល នៅអំឡុងពេលអាពាហ៍ពិពាហ៍ ឬកាតព្វកិច្ច និងករណីយកិច្ចផ្សេងទៀត ដែលប្តីប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរពីប្រពន្ធ ឬប្តីម្ខាងទៀតនៅអំឡុងពេលអាពាហ៍ពិពាហ៍។ ត្រង់មាត្រានេះកូនក្តីរបស់ខ្ញុំបាទមានការទទួលខុសត្រូវដោយសាមគ្គីភាពខ្ពស់ចំពោះកាតព្វកិច្ច ដោយកូនក្តីរបស់ខ្ញុំបាទបានបង់ផ្តាច់នូវការប្រាក់ និងប្រាក់ដើមជាមួយធនាគារអេស៊ីលីដារួចហើយ និងបានជួយបង់ការប្រាក់ជាមួយធនាគារប្រាសាក់ទៀតផង ចំណែកភាគីចុងចម្លើយ គឺបានគេចវេសមិនបានបង់ការប្រាក់ និងប្រាក់ដើមទៅធនាគារប្រាសាក់វិញទេ។ ហេតុដូច្នេះខ្ញុំបាទសុំឱ្យតុលាការចេញសាលក្រមតាមការទាមទារខាងលើនេះ។

៣.២.ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] វ៉ាន បានសូមធ្វើសេចក្តីថ្លែងការណ៍តបថា៖ ខ្លួនឯកភាពទៅតាមការលើកឡើង និងប្តឹងទាមទាររបស់ដើមចោទទាំងស្រុងគឺ៖ ឯកភាពលើការលែងលះ ឯកភាពក្នុងការផ្តល់សិទ្ធិគ្រប់គ្រងកូនម្នាក់ឈ្មោះ [redacted] វឌ្ឍនៈ ភេទប្រុស អាយុ០៣ឆ្នាំ ឱ្យទៅខាងដើមចោទជាអ្នកមានសិទ្ធិអំណាចមេបា និងធានារ៉ាប់រងក្នុងការសងបំណុលធនាគារលើទឹកប្រាក់ចំនួន ៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក។

**៤.ចំណុចវិវាទ៖ គ្មាន។**

## <u>**សំអាងហេតុ**</u>

តាមលទ្ធផលនៃការពិនិត្យនស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១.ឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] វ៉ាន ពិតជាបានរៀបការ និងចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចមានបញ្ជាក់ក្នុងសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ២៤ នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍លេខ៖ ០១/២០១៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ប្រាកដមែន។



Scanned with CamScanner

២.ក្រោយពេលរៀបអាពាហ៍ពិពាហ៍ គូភាគីពិតជារស់នៅមិនចុះសម្រុងនឹងគ្នា និងមិនសូវបានយកចិត្តទុកដាក់នឹងគ្នា ដែលធ្វើឱ្យគូភាគីអស់មនោសញ្ចេតនារស់នៅជាមួយគ្នា ប្រាកដមែន។

៣.តាមការអះអាងរបស់គូភាគីបានបញ្ជាក់ឱ្យឃើញថា ភាគីទាំងពីរ ពិតជាមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ប្រាកដមែន គប្បីតុលាការសម្រេចតាមការព្រមព្រៀងនេះ តាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

៤.ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] វ៉ាន បង្កើតកូនបានចំនួន ០១នាក់ ឈ្មោះ [redacted] វណ្ណន: ភេទស្រី អាយុ ០៣ឆ្នាំ ដូចមាននៅក្នុងសៀវភៅគ្រួសារលេខ៖ ១៤៩០៨/២០១៩ ប្រាកដមែន ហើយគូភាគីបានពិភាក្សា និងឯកភាពគ្នាកំណត់យកម្ដាយឈ្មោះ [redacted] លក្ខិណា ជាអ្នកមានអំណាច មេបាលើកូនឈ្មោះ [redacted] វណ្ណន: គប្បីតុលាការសម្រេចតាមការព្រមព្រៀងនេះ តាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។

៥.គូភាគីបានពិភាក្សា និងព្រមព្រៀងគ្នាបែងចែកបំណុលរួមដូចខាងក្រោម៖

-បំណុលធនាគារលើទឹកប្រាក់ចំនួន ៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក ចុងចម្លើយឈ្មោះ [redacted] វ៉ាន ជាអ្នកទទួលបន្ទុកសងបំណុលក្នុងតែម្នាក់ឯង។

៦.ចំពោះអាហារកាតព្វកិច្ចចិញ្ចឹមកូន ដើមចោទមិនបានទាមទារនោះទេ គប្បីតុលាការមិនលើកយកមកពិចារណាទេ។

៧.ដើមចោទប្ដឹងសុំឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី គប្បីតុលាការសម្រេចតាមការប្ដឹងសុំ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១.ឱ្យដើមចោទឈ្មោះ [redacted] លក្ខិណា លែងលះពីចុងចម្លើយឈ្មោះ [redacted] វ៉ាន តាមការព្រមព្រៀង។

២.កំណត់យកម្ដាយឈ្មោះ [redacted] លក្ខិណា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] វណ្ណន: ភេទប្រុស កើតនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨។

៣.ចំពោះបំណុលរួមសរុបចំនួន ៧.០០០(ប្រាំពីរពាន់)ដុល្លារអាមេរិក ចុងចម្លើយឈ្មោះ [redacted] វ៉ាន ជាអ្នកទទួលបន្ទុកសងបំណុលក្នុងតែម្នាក់ឯង។

៤.ចុងចម្លើយជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី។

៥.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅចំពោះមុខគូភាគី។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ៨កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅមណ្ឌលគិរី,ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner